កំណត់ត្រាសង្ខេបរបស់ ម.ស.ម.ក

រាជធានីភ្នំពេញ ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១២

ទិដ្ឋភាពទូទៅនៃអភ័យឯកសិទ្ធិសភាតាមច្បាប់កម្ពុជា

សេចក្តីផ្តើម៖

កំណត់ត្រាសង្ខេបនេះផ្តល់នូវទិដ្ឋភាពទូទៅអំពីស្ថានភាពនៃអភ័យឯកសិទ្ធិសភាតាមច្បាប់កម្ពុជា ក្រោយពីបានពិចារណាលើការជំនុំជម្រះរបស់សាលាឧទ្ធរណ៍នៅរាជធានីភ្នំពេញកាលពីថ្ងៃទី៣ ខែសីហា ឆ្នាំ២០១២ ដែលអភ័យឯកសិទ្ធិសភារបស់លោកស្រី សុខហួរ ជាតំណាងរាស្ត្រដ៏ល្បីឈ្មោះមួយរូបមកពីគណបក្ស សម រង្ស៊ី (“គ.ស.រ”) ដែលជាគណបក្សជំទាស់ ត្រូវបានប្រគល់ជូនទៅលោកស្រីវិញ។ ការដកអភ័យឯកសិទ្ធិសភារបស់លោកស្រី សុខហួរ គួសបញ្ជាក់ពីកំហុសឆ្គងក្នុងច្បាប់ពាក់ព័ន្ធទាំងឡាយ ជុំវិញបញ្ហាអភ័យឯកសិទ្ធិសភា ដែលត្រូវតែធ្វើការដោះស្រាយដើម្បីជាអត្ថប្រយោជន៍ដល់លទ្ធិប្រជាធិបតេយ្យនៅក្នុងព្រះរាជាណាចក្រកម្ពុជា (“កម្ពុជា”)។

ករណីរបស់លោកស្រី សុខហួរ ពុំមែនជាករណីតែមួយនោះទេ តែនេះជាឧទាហរណ៍មួយផ្សេងទៀតនៃកម្រិតដែលរាជរដ្ឋាភិបាលកម្ពុជា (“រ.រ.ក”) កំពុងតែបង្ហាញឆន្ទៈរបស់ខ្លួនក្នុងការបំភិតបំភ័យលើសំឡេងប្រឆាំង។ គណបក្សប្រជាជនកម្ពុជា (“គ.ប.ក”) ដែលកំពុងកាន់អំណាចបានបតបង្ហាញនូវកំណត់ត្រាតាមដានដែលបានបង្ហាញយ៉ាងជាក់លាក់ក្នុងការប្រើប្រាស់អាសនៈភាគច្រើនចំនួន៩០ ក្នុងចំណោមអាសនៈ១២៣ របស់ខ្លួននៅក្នុងរដ្ឋសភា ដើម្បីដកអភ័យឯកសិទ្ធិសភារបស់សមាជិកជំទាស់ ដែលជាការត្រួសត្រាយផ្លូវសម្រាប់ចំណាត់ការតុលាការដោយស្ថាប័នតុលាការដែលងាយបត់បែនតាមលក្ខណៈនយោបាយរបស់ប្រទេស។ ករណីផ្សេងទៀត ដែលឈានដល់ការដកអភ័យឯកសិទ្ធិសភារបស់សមាជិកជំទាស់នៅក្នុងរដ្ឋសភា រួមបញ្ចូលទាំងប្រធានគណបក្សជំទាស់លោក សម រង្ស៊ី និងអ្នកតំណាងរាស្ត្រ ចាន់ ចេង មកពី គ.ស.រ ធ្វើឲ្យសេចក្តីសន្និដ្ឋានលើបញ្ហានេះរឹតតែរឹងមាំ ដែលបង្កើតជាគំរូនៃការវាយប្រហារតាមផ្លូវតុលាការប្រឆាំងនឹងអ្នកជំទាស់ក្នុងប្រទេសកម្ពុជា។ ករណីផ្សេងៗទាំងនេះ ដែលនឹងត្រូវយក

មកពិភាក្សាជាបន្តបន្ទាប់នៅក្នុងកំណត់ត្រាសង្ខេបនេះ បង្កើតនូវបរិបទមួយដែលករណីរបស់លោកស្រី សុខហួរ គួរតែត្រូវបានគេយល់ដឹង។

អភ័យឯកសិទ្ធិសភា ដែលត្រូវបានគេដឹងផងដែរថាជាអភ័យឯកសិទ្ធិតំណាងរាស្ត្រ គឺជាយន្តការមួយដែលសមាជិកសភា ឬតំណាងរាស្ត្រ ត្រូវបានផ្តល់ជូននូវអភ័យឯកសិទ្ធិមួយ ដែលធ្វើឲ្យពួកគេអាចរួចផុតពីការផ្តន្ទាទោស។ នេះគឺជាការធានាសុវត្ថិភាពតាមផ្លូវច្បាប់ដ៏សំខាន់ ដែលអាចឲ្យតំណាងរាស្ត្រទាំងឡាយអាចនិយាយដោយបើកចំហរ និងសេរី ព្រមទាំងដើម្បីអាចបំពេញតួនាទីជាតំណាងរាស្ត្រដោយពុំភ័យខ្លាចអំពីការផ្តន្ទាទោស។ សិទ្ធិសេរីភាពបញ្ចេញមតិត្រូវបានធានាដោយច្បាប់កម្ពុជា៖ មាត្រា៤១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (“រដ្ឋធម្មនុញ្ញ”) ចែងថាប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន។ មាត្រា៣១ ចែងថាប្រទេសកម្ពុជាទទួលស្គាល់ និងគោរពសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (“ស.ស.ស.ម”) និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយដែលទាក់ ទងនឹងសិទ្ធិមនុស្ស ដែលរួមបញ្ចូលទាំងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (“ក.អ.ស.ព.ន”)។ ម្យ៉ាងវិញទៀត ក.អ.ស.ព.ន ត្រូវបានបញ្ចូលដោយផ្ទាល់ទៅក្នុងច្បាប់ជាតិរបស់កម្ពុជា ដែលប្រទេសកម្ពុជាឲ្យសច្ចាប័ននៅក្នុងឆ្នាំ១៩៩២ ហើយការបញ្ចូលបែបនេះត្រូវបានបញ្ជាក់ដោយសេចក្តីសម្រេចមួយរបស់ក្រុមប្រឹក្សាធម្មនុញ្ញ កាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ ដែលបានចែងថា *“អនុសញ្ញាអន្តរជាតិទាំងឡាយដែលកម្ពុជាទទួលស្គាល់”* បង្កើតជាផ្នែកមួយនៃច្បាប់កម្ពុជា។[1] មាត្រា១៩ នៃ ស.ស.ស.ម និង ក.អ.ស.ព.ន ផ្តល់នូវសិទ្ធិសេរីភាពខាងការបញ្ចេញមតិរបស់បុគ្គលគ្រប់រូប។ បន្ថែមលើនេះទៀត មាត្រា ៣៥ នៃរដ្ឋធម្មនុញ្ញបញ្ញត្តថាប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយរបស់ប្រទេសជាតិ។ មុនមានការផ្តន្ទាទោសសមាជិកណាម្នាក់នៃរដ្ឋសភា ជាការចាំបាច់គឺថាអភ័យឯកសិទ្ធិសភារបស់ពួកគេត្រូវបានដកជាមុនសិន។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើអភ័យឯកសិទ្ធិសភាអាចត្រូវបានដកហូតតាមអំពើចិត្ត នោះអភ័យ-ឯកសិទ្ធិនេះនឹងលែងមានប្រសិទ្ធភាព ហើយនាំឲ្យគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សេរីភាពខាងការបញ្ចេញមតិ និងលទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេស។

ច្បាប់ស្តីពីលក្ខន្តិកតំណាងរាស្ត្រ (“ច.ល.ត.រ”) ប្រហែលជាអាចឆ្លុះបញ្ចាំងយ៉ាងប្រសើរបំផុតអំពីកម្រិតនៃប្រសិទ្ធភាពដែលរាជរដ្ឋាភិបាលកម្ពុជា កំពុងតែប្រើប្រាស់ស្ថាប័នតុលាការដែលបម្រើឲ្យខ្លួនក្នុងការបំពានលើក្របខណ្ឌនៃអង្គនីតិបញ្ញត្តិរឹតតែខ្លាំងទៅៗ និងគំរាមកំហែងដល់តំណាងរាស្ត្រ ដែលត្រូវបានជ្រើសតាំងតាមបែបលទ្ធិប្រជាធិបតេយ្យ ហើយដែលផ្ទុយទៅនឹងមាត្រា៨០ នៃរដ្ឋធម្មនុញ្ញ ដែលបញ្ញត្តថា

[1] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា លេខ០៩២/០០៣/២០០៧ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ ២០០៧។

តំណាងរាស្ត្ររូបណាក៏ដោយមិនអាចត្រូវបានចោទប្រកាន់ ឃាត់ខ្លួន ឬឃុំខ្លួន ដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ។[2] ច.ល.ត.រ ដែលបានអនុម័តដោយរដ្ឋសភា នៅឆ្នាំ២០០៦ រឹតត្បិតយ៉ាងខ្លាំងដល់សិទ្ធិរបស់តំណាងរាស្ត្រក្នុងការបញ្ចេញមតិយោបល់ដោយសេរី។ ចាប់តាំងពីការអនុម័ត ច.ល.ត.រ ករណីដែលតំណាងរាស្ត្រត្រូវបានដកអភ័យឯកសិទ្ធិសភា និងបន្ទាប់មកត្រូវបានចោទប្រកាន់ពីបទបរិហារកេរ្តិ៍ត្រូវបានសង្កេតឃើញថាមានការកើនឡើងគួរឲ្យកត់សម្គាល់។

ករណីប្រឆាំងនឹងអ្នកស្រី សុខហួរ៖

អ្នកស្រី សុខហួរ គឺជាតំណាងរាស្ត្រមកពី គ.ស.រ ដែលជាគណបក្សជំទាស់ដ៏ធំមួយ និងជាដៃគូមួយនៅក្នុងគណបក្សសង្គ្រោះជាតិ (“គ.ស.ជ”) ដែលទើបតែបង្កើតថ្មី។ អ្នកស្រី សុខហួរ ត្រូវបានជ្រើសតាំងកាលពីឆ្នាំ២០០៨ ជាតំណាងរាស្ត្រមណ្ឌលខេត្តកំពត។ អ្នកស្រីគឺជាសំឡេងដ៏លេចធ្លោមួយនៅក្នុង គ.ស.រ ជាពិសេសក្នុងខណៈពេលដែលលោក សម រង្ស៊ី ដែលជាប្រធានកំពុងនិរទេសខ្លួន និងប្រឈមនឹងការចាប់ខ្លួន បើសិនជាគាត់ត្រឡប់មកប្រទេសកម្ពុជាវិញនោះ។ ករណីរបស់អ្នកស្រីគូសបញ្ជាក់ពី ភាពមិនស៊ីសង្វាក់គ្នាជាច្រើននៅក្នុងប្រព័ន្ធច្បាប់កម្ពុជា និងច្បាប់ជាតិ។

កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ អ្នកស្រី សុខហួរ បានដាក់ពាក្យបណ្តឹងប្រឆាំងនឹងលោកនាយករដ្ឋមន្ត្រីដោយចោទពីបទបរិហារកេរ្តិ៍តាមមាត្រា៦៣ នៃច្បាប់ព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាលរបស់អង្គការសហប្រជាជាតិ (“ច្បាប់អ៊ុនតាក់”) ជាការឆ្លើយតបទៅនឹងសុន្ទរកថាដែលលោកនាយករដ្ឋមន្ត្រីសំដៅលើតំណាងរាស្ត្រជាស្ត្រីមកពីគណបក្សជំទាស់ដោយមិនបានបញ្ជាក់ឈ្មោះ ហើយដែលអ្នកស្រី សុខហួរ គឺអាចកំណត់អត្តសញ្ញាណបានដោយងាយស្រួលនៅក្នុងបរិបទនៃសេចក្តីថ្លែងការណ៍ដែលថាជា *“ជើងខ្លាំង”* ដែលជាពាក្យប្រមាថដែលបញ្ជាក់ថានរណាម្នាក់ជាអ្នកលេង និង/ឬ ជាពិសេសស្រីពេស្យា នៅពេលដែលប្រើសំដៅទៅលើស្ត្រី។[3]

បន្ទាប់ពីលោក ហ៊ុន សែន បានបដិសេធពុំកែប្រែការអត្ថាធិប្បាយរបស់គាត់ អ្នកស្រី សុខហួរ បានដាក់ពាក្យបណ្តឹងទាមទារសំណងជានិមិត្តរូបចំនួន៥០០រៀល។ លោកនាយករដ្ឋមន្ត្រីបានឆ្លើយតប

---

[2] *សេចក្តីប្រកាសព័ត៌មានរបស់គណៈកម្មការសិទ្ធិមនុស្សអាស៊ាន* ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៦៖“កម្ពុជា៖ ច្បាប់លុបចោលអភ័យឯកសិទ្ធិសភាគឺមិនស្របនឹងរដ្ឋធម្មនុញ្ញ និងមិនអាចទទួលយកបាន” អាចស្វែងរកបានតាមរយៈ៖ http://www.humanrights.asia/news/ahrc-news/AS-215-2006.

[3] *វិទ្យុអូស្ត្រាលី* ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២៖“តំណាងរាស្ត្រគណបក្សប្រឆាំងនឹងប្តឹងលោក ហ៊ុន សែន ពីបទបរិហារកេរ្តិ៍” បទសម្ភាសន៍តាមវិទ្យុរវាងលោក រ៉ូបឺត ខាមីឃែល និងអ្នកស្រី មួរ សុខហួរ ដែលអាចស្វែងរកបានតាមរយៈ៖ http://www.radioaustralia.net.au/connectasia/stories/200904/s2551808.htm.

តាមរយៈការដាក់ពាក្យបណ្តឹងតបដោយអះអាងថាអ្នកស្រី សុខហួរ បានបរិហារកេរ្តិ៍លើរូបគាត់ ដោយសេចក្តីអត្ថាធិប្បាយដែលបានចោទថាភាសាប្រមាថរបស់នាយករដ្ឋមន្ត្រីបានធ្វើឲ្យប៉ះពាល់ដល់ស្ត្រីខ្មែរគ្រប់រូប។ មានការគំរាមដាក់ពាក្យបណ្តឹងបរិហារកេរ្តិ៍មកលើមេធាវីរបស់អ្នកស្រី សុខហួរ ផងដែរ ដោយបង្ខំឲ្យមេធាវីទម្លាក់ករណីនេះចោល និងដកហូតសិទ្ធិរបស់អ្នកស្រីក្នុងការជ្រើសរើសអ្នកតំណាងតាមផ្លូវច្បាប់ដោយខ្លួនឯង។ កាលពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ សាលាដំបូងរាជធានីភ្នំពេញបានច្រានចោលករណីប្រឆាំងនឹងលោកនាយករដ្ឋមន្ត្រី ដោយនិយាយថាពុំមានមូលដ្ឋានច្បាស់លាស់។ លោកព្រះរាជអាជ្ញារង ហ៊ឹង ប៊ុនជា បានពន្យល់នៅក្នុងសេចក្តីថ្លែងការណ៍ចំនួនបីទំព័រថា ដោយសារតែបទអត្ថាធិប្បាយរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន មិនបានសំដៅដោយចំឈ្មោះលើអ្នកស្រី សុខហួរ និងលោកនាយករដ្ឋមន្ត្រីពុំមានចេតនាបន្ទោសបង្អាប់ចំពោះបុគ្គលណាម្នាក់តាមរយៈសេចក្តីអត្ថាធិប្បាយរបស់គាត់ទេនោះ នោះពាក្យបណ្តឹងគឺពុំមានសុពលភាពទេ។[4] ការលើកឡើងហេតុផលបែបនេះគឺជាការអនុវត្តន៍ខុសយ៉ាងច្បាស់នូវមាត្រា៦៣ នៃច្បាប់អ៊ុនតាក់ ដែលបញ្ញត្តថា *"ការផ្សាយដោយផ្ទាល់ ឬផ្សាយបន្តនូវការពោលអះអាងនោះ ឬការទម្លាក់កំហុសនោះ ត្រូវមានទោស <u>ទោះបីសំដៅទៅលើជនណាមួយ ដោយមិនបញ្ចេញឈ្មោះដាក់លាក់ក៏ដោយ ប៉ុន្តែកិនភាគបានបញ្ជាក់ច្បាស់តាមន័យក្នុងសុន្នរកថា តាមសម្រែក តាមការគំរាមកំហែង តាមការសរសេរឬតាមការបោះពុម្ព តាមផ្ទាំងបដាឬប័ណ្ណប្រកាស តាមការផ្សាយសោតទស្សន៍ដែលជាប់ចោទ។"</u>*[5]

តុលាការបានចាត់ការបន្តជាមួយនឹងពាក្យបណ្តឹងតបរបស់លោកនាយករដ្ឋមន្ត្រី។ សវនាការរបស់អ្នកស្រី សុខហួរ ជាប់ពាក់ព័ន្ធដោយផ្ទាល់ (និងប្រយោល) ជាមួយនឹងចៅក្រមជាច្រើនរូប ដែលស្ថិតក្នុងតួនាទីដែលអាចជះឥទ្ធិពលដល់ដំណើរការតាមផ្លូវច្បាប់ និងដែលមានទំនាក់ទំនងយ៉ាងច្បាស់លាស់ជាមួយនឹងលោកនាយករដ្ឋមន្ត្រី និងគណបក្សរបស់លោកគឺ គ.ប.ក។ ជាចុងក្រោយ អ្នកស្រី សុខហួរ ត្រូវបានរកឃើញពីពិរុទ្ធភាពក្នុងបទបរិហារកេរ្តិ៍ និងត្រូវបានពិន័យជាប្រាក់ចំនួន ១៦,៥ លានរៀល ដែលជាប្រាក់ពិន័យ និងសំណងជំងឺចិត្ត។ អ្នកស្រីបានបដិសេធមិនបង់ប្រាក់ពិន័យទាំងនេះ ដោយនិយាយថាអ្នកស្រីសុខចិត្តជាប់ពន្ធនាគារជំនួសវិញ។ គ្មានលទ្ធផលបែបនេះកើតឡើងនោះទេដោយសារចំនួនទឹកប្រាក់ដែលអ្នកស្រីជំពាក់ត្រូវបានទូទាត់ជំនួសដោយការដកយកប្រាក់បៀវត្សរបស់អ្នកស្រីក្នុងនាមជាតំណាងរាស្ត្រ។ តាមរយៈការពិនិត្យលើក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ("ក្រ.នី.ព្រ ២០០៧") និងច្បាប់

[4] *ម.ស.ម.ក* ខែឧសភា ឆ្នាំ២០១២៖"វិភាគផ្នែកច្បាប់៖ ករណីរបស់ព្រះរាជាណាចក្រកម្ពុជា ទល់នឹងអ្នកស្រី មួរ សុខហួរ" អាចស្វែងរកបានតាមរយៈ៖
http://www.cchrcambodia.org/index_old.php?url=media/media.php&p=analysis_detail.php&anid=11&id=5.

[5] ឃ្លាដែលគូសបន្ទាត់ពីក្រោមដើម្បីសង្កត់ធ្ងន់

អ៊ុនតាក់ បានបង្ហាញថាការធ្វើរបៀបនេះត្រូវបានធ្វើឡើងដោយគ្មានមូលដ្ឋានច្បាប់ច្បាស់លាស់ ដែលជាការពិតត្រូវបានរៀបចំឡើងដើម្បីបញ្ចៀសការប្តោលទោសជាតិ និងអន្តរជាតិនានា។ នៅក្នុងករណីណាក៏ដោយ ការធ្វើបែបនេះមិនមែនជាការសម្រេចដាក់ទណ្ឌកម្មដោយតុលាការនោះទេ។[6]

ករណីបទបរិហារកេរ្តិ៍ប្រឆាំងនឹងអ្នកស្រី សុខហួរ បានធ្វើឲ្យមានការប្តោលទោសទាំងក្នុងស្រុក និងនៅបរទេស ព្រមទាំងត្រូវបានមើលឃើញយ៉ាងទូលាយថាជាអំពើយាយីរបស់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសក្រោយពីបានពិចារណាអំពីភាពផ្ទុយគ្នានៅក្នុងចំណាត់ការដែលបណ្តឹងបរិហារកេរ្តិ៍របស់អ្នកស្រី សុខហួរ ប្រឆាំងនឹងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ត្រូវបានច្រានចោលភ្លាមៗ នៅខណៈដែលបណ្តឹងតបរបស់លោកនាយករដ្ឋមន្ត្រីត្រូវបានចាត់ការ ថ្វីត្បិតពុំមានហេតុផលដែលគួរឲ្យជឿជាក់ត្រូវបានផ្តល់ជូនដើម្បីជាការគាំទ្របណ្តឹងតបនោះ។[7] ហេតុដូច្នេះ ករណីនេះបានធ្វើឲ្យមានមន្ទិលសង្ស័យអំពីឯករាជ្យភាពនៃស្ថាប័នតុលាការ ដែលត្រូវបានចែងក្នុងមាត្រា១២៨ នៃរដ្ឋធម្មនុញ្ញ ជាមួយនឹងការចោទប្រកាន់ជាច្រើនដែលថាអង្គនីតិប្រតិបត្តិអាចជះឥទ្ធិពលដល់សេចក្តីសម្រេចរបស់តុលាការ។ នៅពេលបណ្តឹងឧទ្ធរណ៍របស់អ្នកស្រី ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា (“ក.ឧ.ស.ម.ក”) បានថ្លែងថា *“ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌគឺជាគ្រឹះនៃការការពារសិទ្ធិមនុស្ស។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងករណីនេះ តុលាការបានក្លាយជាឧបករណ៍ដោយផ្ទាល់ក្នុងការបំបិទសេរីភាពខាងការបញ្ចេញមតិ។”*

អ្នកស្រី សុខហួរ បានរង់ចាំការផ្តល់អភ័យឯកសិទ្ធិសភាឡើងវិញអស់រយៈពេលបីឆ្នាំ។ ឥឡូវនេះ បន្ទាប់ពីមានការពន្យារ និងភាពច្របូកច្របល់ជាច្រើនថាតើអ្នកណាជាអ្នកទទួលខុសត្រូវសម្រាប់ការផ្តល់អភ័យឯកសិទ្ធិសភាឡើងវិញ អ្នកស្រី សុខហួរ ត្រូវបានជូនដំណឹងដោយសាលាឧទ្ធរណ៍ ដែលថាសវនាការនឹងប្រព្រឹត្តទៅនៅថ្ងៃទី៣ ខែសីហា ឆ្នាំ២០១២។ អភ័យឯកសិទ្ធិសភារបស់អ្នកស្រីត្រូវបានផ្តល់ជូនឡើងវិញយ៉ាងត្រឹមត្រូវ តែមិនមែនជាដំណើរការដ៏ងាយស្រួលនោះទេ៖ សវនាការបានធ្វើឡើងអស់រយៈពេលមួយម៉ោង ក្នុងអំឡុងពេលនោះប្រធានក្រុមប្រឹក្សាជំនុំជម្រះ លោកចៅក្រម ជួន ស៊ុនឡេង បានសាកសួរអំពី“សីលធម៌សង្គម”របស់អ្នកស្រី សុខហួរ ជាលទ្ធផលនៃរបាយការណ៍មួយរបស់អគិបាលរាជធានីភ្នំពេញ លោក កែប ជុតិមា ដែលបានចោទប្រកាន់ការបំពានតួនាទីរបស់អ្នកស្រីក្នុងការដោះលែង

---

[6] មាស សុខជា “ប្រាក់ពិន័យរបស់អ្នកស្រី សុខហួរ ត្រូវបានកាត់សម្រាប់ទូទាត់” *ឌីភ្នំពេញប៉ុស្តិ៍* ថ្ងៃទី១២ ខែសីហា ឆ្នាំ២០១២ អាចស្វែងរកបានតាមរយៈ៖ http://www.phnompenhpost.com/index.php/2010081241186/National-news/sochua-fine-to-be-docked-from-pay.html.

[7] *ម.ស.ម.ក* ខែឧសភា ឆ្នាំ២០១០៖“វិភាគផ្នែកច្បាប់៖ ករណីរបស់ព្រះរាជាណាចក្រកម្ពុជា ទល់នឹងអ្នកស្រី មួរ សុខហួរ” អាចស្វែងរកបានតាមរយៈ៖
http://www.cchrcambodia.org/index_old.php?url=media/media.php&p=analysis_detail.php&anid=11&id=5.

ស្ត្រី១៨នាក់ ដែលត្រូវបានឃុំខ្លួនតាមទំនើងចិត្តនៅមណ្ឌលឃុំខ្លួនព្រៃស្គីកាលពីដើមឆ្នាំនេះ។[8] ជាលទ្ធផលបណ្តឹងពីបទញុះញង់ត្រូវបានប្តឹងប្រឆាំងនឹងអ្នកស្រី សុខហួរ ហើយសេចក្តីសម្រេចរបស់ចៅក្រមចំពោះឧប្បត្តិហេតុនេះគឺគ្រាន់បើច្រើនជាងការគំរាមកំហែងកំបាំងមុខ។ ការឃុំខ្លួនស្ត្រីទាំងនេះត្រូវបានធ្វើឡើងបន្ទាប់ពីការបណ្តេញចេញដោយបង្ខំពីសហគមន៍បុរីកីឡា រាជធានីភ្នំពេញ ព្រមទាំងការបំពារបំពាន និងការចាប់ខ្លួនជាបន្តបន្ទាប់នៅពេលធ្វើការទាមទារដោយសន្តិវិធីបានធ្វើឲ្យមានការរិះគន់យ៉ាងខ្លាំងក្លាពីសំណាក់ក្រុមការងារសិទ្ធិមនុស្សជាតិ និងអន្តរជាតិរួមទាំងមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (“ម.ស.ម.ក”) អង្គការលើកលែងទោសអន្តរជាតិ និងអង្គការឃ្លាំមើលសិទ្ធិមនុស្ស។[9] របាយការណ៍របស់លោក កែប ជុតិមា បានសរសេរថា៖ *“អ្នកស្រី សុខហួរ តែងតែញុះញង់ឲ្យប្រជាពលរដ្ឋធ្វើសកម្មភាពផ្សេងៗដែលប្រឆាំងនឹងរដ្ឋាភិបាល ថ្វីបើខ្លួនពុំមានអភ័យឯកសិទ្ធិក្តី”* ជាការចោទប្រកាន់ដែលត្រូវបានជំទាស់ដោយអ្នកស្រី សុខហួរ ដែលអះអាងថាក្នុងនាមជាតំណាងរាស្ត្រ នេះជាភារកិច្ចរបស់អ្នកស្រីក្នុងការការពារសិទ្ធិរបស់ប្រជាជន។[10] ជាចុងក្រោយ លោកចៅក្រម ស៊ុនឡេង បានយល់ព្រមក្នុងការផ្តល់អភ័យឯកសិទ្ធិសការបស់អ្នកស្រី សុខហួរ ល្ឿកណាតែគ្មានបណ្តឹងឧបាស្រ័យត្រូវបានទទួលក្នុងរយៈពេល៣០ថ្ងៃបន្ទាប់ពីថ្ងៃសវនាការ។ ពុំមានបណ្តឹងឧបាស្រ័យត្រូវបានដាក់ទេ ហេតុដូច្នេះអភ័យឯកសិទ្ធិរបស់អ្នកស្រីត្រូវបានផ្តល់ឲ្យឡើងវិញយ៉ាងត្រឹមត្រូវ។

ក្នុងអំឡុងពេលបីឆ្នាំនេះមានព័ត៌មានជាច្រើន៖ ដូចដែលលោក រ៉ុង ឈុន សកម្មជនសហជីពគាំទ្រគណបក្សជំទាស់បានកត់សម្គាល់ថា៖ *“ដោយសារតែអ្នកស្រី សុខហួរ ជាសមាជិកគណបក្សជំទាស់ តុលាការចំណាយពេលដល់ទៅបីឆ្នាំដើម្បីផ្តល់អភ័យឯកសិទ្ធិដល់អ្នកស្រី... ប្រសិនជាអ្នកស្រី សុខហួរ ជាសមាជិកគណបក្សគ្រប់គ្រងអំណាច តុលាការប្រហែលជានឹងផ្តល់អភ័យឯកសិទ្ធិដល់អ្នកស្រីវិញក្នុងរយៈពេលត្រឹមតែបីថ្ងៃ។”*[11]

---

[8] *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី៦ ខែសីហា ឆ្នាំ២០១២៖“តុលាការសម្រេចគាំទ្រខាងអ្នកស្រី មួរ សុខហួរ” អាចស្វែងរកបានតាមរយៈ៖ http://www.phnompenhpost.com/index.php/2012080657834/National-news/court-comes-down-on-sochuas-side.html.

[9] *អង្គការឃ្លាំមើលសិទ្ធិមនុស្ស អង្គការលើកលែងទោសអន្តរជាតិ ហ្វអាយឌីអេហ្វ អេត៍អាល់* ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១២៖ “លិខិតរួមជូនចំពោះនាយករដ្ឋមន្ត្រីកម្ពុជាពាក់ព័ន្ធនឹងការបណ្តេញចេញដោយបង្ខំនៅបុរីកីឡា” អាចស្វែងរកបានតាមរយៈ៖ http://www.hrw.org/news/2012/01/23/joint-letter-cambodian-prime-minister-regarding-borei-keila-forced-eviction.

[10] *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី៦ ខែសីហា ឆ្នាំ២០១២៖“តុលាការសម្រេចគាំទ្រខាងអ្នកស្រី មួរ សុខហួរ” អាចស្វែងរកបានតាមរយៈ៖ http://www.phnompenhpost.com/index.php/2012080657834/National-news/court-comes-down-on-sochuas-side.html.

[11] *វិទ្យុសម្លេងសហរដ្ឋអាមេរិក (វីអូអេ)* ថ្ងៃទី៨ ខែសីហា ឆ្នាំ២០១២៖“បីឆ្នាំក្រោយមក អភ័យឯកសិទ្ធិសការបស់អ្នកស្រី មួរ សុខហួរ ត្រូវបានផ្តល់ជូនឡើងវិញ” អាចស្វែងរកបានតាមរយៈ៖ http://www.voacambodia.com/content/after-three-years-mu-sochua-parliamentary-immunity-restored/1454897.html.

ទោះជាយ៉ាងណាក៏ដោយ ការពិនិត្យមើលល្អិតល្អន់លើច្បាប់ពាក់ព័ន្ធនឹងអភ័យឯកសិទ្ធិសភា បង្ហាញពីកំហុសឆ្គង និងភាពមិនស្របគ្នាជាច្រើននៅក្នុងសេចក្តីសម្រេច ដើម្បីដកអភ័យឯកសិទ្ធិសភារបស់អ្នកស្រី សុខហួរ កាលពីដំបូង ជាមួយនិងដំណើរការអូសបន្លាយ និងប្រកបដោយគុណវិបត្តិតាមផ្លូវច្បាប់ ក្នុងការផ្តល់អភ័យឯកសិទ្ធិដល់អ្នកស្រីវិញ។ នេះជាការសំខាន់ដែលថាភាពមិនច្បាស់លាស់ត្រូវបានលុបបំបាត់នៅក្នុងដំណាក់កាលដំបូងបំផុត ដើម្បីជៀសវាងករណីបែបនេះនៅពេលអនាគត ដែលអភ័យឯកសិទ្ធិសភាត្រូវបានដកដោយខុសច្បាប់បែបនេះ និងកែតម្រូវដំណើរការតាមអំពើចិត្តដែលអ្នកស្រី សុខហួរ ត្រូវអត់ធ្មត់ទ្រាំទទួល ដើម្បីធានាថាបុព្វសិទ្ធិ និងការធានាសុវត្ថិភាពសភាដ៏ចាំបាច់ត្រូវបានគោរពយ៉ាងត្រឹមត្រូវ និងតាមផ្លូវច្បាប់។

អភ័យឯកសិទ្ធិសភាតាមច្បាប់កម្ពុជា៖

មាត្រា៨០ នៃរដ្ឋធម្មនុញ្ញចែងពីអភ័យឯកសិទ្ធិសភាសម្រាប់តំណាងរាស្ត្រ៖ *"តំណាងរាស្ត្រមានអភ័យឯកសិទ្ធិសភា។ តំណាងរាស្ត្ររូបណាក៏ដោយមិនអាចត្រូវបានចោទប្រកាន់ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួន ដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ។"* បញ្ញត្តិនេះត្រូវបានឆ្លុះបញ្ចាំងក្នុងមាត្រា៤ នៃច.ល.ត.រ៖ *"តំណាងរាស្ត្រមានអភ័យឯកសិទ្ធិសភា។"*

ការដកអភ័យឯកសិទ្ធិសភា

មាត្រា១៤ នៃច.ល.ត.រ បញ្ញត្តអំពីលក្ខខណ្ឌដែលអភ័យឯកសិទ្ធិសភាអាចត្រូវបានដក៖ "តំណាងរាស្ត្រដែលមានសាលក្រមស្ថាពរ ឬ សាលដីកាស្ថាពរសម្រេចថាជាទណ្ឌិតជាប់ពន្ធនាគារត្រូវបាត់បង់ទាំងស្រុងនូវសិទ្ធិ បុព្វសិទ្ធិ និងសមាជិកភាពជាសមាជិករដ្ឋសភា។"[12] ផ្ទុយទៅវិញ ច.ល.ត.រ ពុំមានកំណត់អំពីវិធានការទៅលើតំណាងរាស្ត្រ ប្រសិនបើតំណាងរាស្ត្រនោះត្រូវបានផ្តន្ទាទោសដោយពុំមានទោសជាប់ពន្ធនាគារ ដែលច្បាប់នេះពុំបានផ្តល់ជាមូលដ្ឋានសម្រាប់ការដកអភ័យឯកសិទ្ធិសភាក្នុងករណីបែបនេះឡើយ។ ហេតុដែលថាច្បាប់មិនមានកំណត់លើចំណុចនេះគាំទ្រចំពោះទម្លឹកណ៍ដែលថាអភ័យឯកសិទ្ធិសភាមិនគួរត្រូវបានដកហូតក្នុងករណី"បទល្មើស"មិនសំខាន់បែបនេះឡើយ។ ច.ល.ត.រ ក៏ពុំបានផ្តល់នូវការចង្អុលបង្ហាញណាមួយថាអភ័យឯកសិទ្ធិសភាអាចត្រូវបានដកហូតរយៈពេលយូរប៉ុនណានោះទេ។

ដោយសារតែអ្នកស្រី សុខហួរ មិនត្រូវបានតុលាការផ្តន្ទាទោសឲ្យជាប់ពន្ធនាគារ ប៉ុន្តែត្រូវបានសម្រេចឲ្យបង់ប្រាក់ពិន័យជំនួសវិញនោះ ហេតុនេះពុំមានមូលដ្ឋានគតិយុត្តសម្រាប់ការលុបចោលអភ័យឯកសិទ្ធិរបស់អ្នកស្រីនោះទេ។ ក្រៅពីហេតុដែលថាអ្នកស្រីមិនគួរត្រូវបានដកអភ័យឯកសិទ្ធិសភាតាំងពី

[12] ឃ្លាដែលគូសបន្ទាត់ពីក្រោមដើម្បីសង្កត់ធ្ងន់

ដំបូងនោះ ដោយសារតែអ្នកស្រីគ្រាន់តែអនុវត្តសិទ្ធិសេរីភាពជាមូលដ្ឋានក្នុងការបញ្ចេញមតិរបស់ខ្លួនប៉ុណ្ណោះ ហើយការពិតគឺថាពុំមានបញ្ញត្តិជាក់លាក់ណាមួយនៅក្នុង ច.ល.ត.រ ដែលកំណត់អំពីការដកអភ័យឯកសិទ្ធិសភារបស់តំណាងរាស្ត្ររូបណាមួយដែលត្រូវបានសម្រេចថាមានទោស តែមិនទទួលទោសពន្ធនាគារនោះទេ។

នីតិវិធីសម្រាប់ផ្តល់អភ័យឯកសិទ្ធិសភាឡើងវិញតាម ច.ល.ត.រ

ច.ល.ត.រ ចែងអំពីការផ្តល់អភ័យឯកសិទ្ធិសភាឡើងវិញដោយអនុលោមតាមមាត្រា១៥ និង ១៦។ មាត្រា១៥ បញ្ញត្តថា៖ *"តំណាងរាស្ត្ររូបណាមួយជាទណ្ឌិត ហើយត្រូវបានព្រះមហាក្សត្រលើកលែងទោសតំណាងរាស្ត្ររូបនោះនឹងទទួលសុពលភាព អភ័យឯកសិទ្ធិ និងបុព្វសិទ្ធិឡើងវិញ។"* មាត្រា១៦ បញ្ញត្តថា៖ *"តំណាងរាស្ត្រណាដែលមានសាលក្រមស្តាពរ ឬ សាលដីកាស្តាពរសម្រេចថា ជាជនគ្មានទោស តំណាងរាស្ត្រនោះត្រូវបានទទួលជាស្វ័យប្រវត្តិនូវអភ័យឯកសិទ្ធិ និងបុព្វសិទ្ធិពេញលេញឡើងវិញ។"*

ហេតុដូច្នេះ ចំណុចនេះបង្ហាញយ៉ាងច្បាស់លាស់ថាពិតជាមានចន្លោះប្រហោងនៅក្នុង ច.ល.ត.រ ដែលថាតំណាងរាស្ត្ររូបណាដែលត្រូវបានតុលាការរកឃើញថាមានពិរុទ្ធភាពចំពោះបទល្មើសណាមួយ តែមិនទាន់ត្រូវបានលើកលែងទោសដោយព្រះមហាក្សត្រ ឬ មិនទាន់ត្រូវបានប្រកាសថាគ្មានទោស ត្រូវស្ថិតក្នុងស្ថានភាពគតិយុត្តមិនច្បាស់លាស់ទាក់ទិននឹងការផ្តល់អភ័យឯកសិទ្ធិសភាដល់តំណាងរាស្ត្រនោះវិញ។ នេះជាការបរាជ័យយ៉ាងពិតប្រាកដក្នុងការពន្យល់អំពីវិធីដែលសមាជិកនៃ ច.ល.ត.រ ដែលត្រូវបានដកហូតអភ័យឯកសិទ្ធិសភារបស់ខ្លួនអាចឈានទៅទទួលបានអភ័យឯកសិទ្ធិសភាមកវិញ ឬ ថាតើដំណើរការដ៏ជាក់លាក់មួយប្រព្រឹត្តទៅជាស្វ័យប្រវត្តិឬក៏យ៉ាងណានោះ។

យ៉ាងណាមិញ ច.ល.ត.រ ពុំមានភាពច្បាស់លាស់ថាស្ថាប័នមួយណាត្រូវទទួលខុសត្រូវសម្រាប់ផ្តល់អភ័យឯកសិទ្ធិសភាឡើងវិញ។ អវត្តមាននៃសេចក្តីណែនាំគតិយុត្តអំពីវិធីដែលត្រូវដោះស្រាយចំពោះករណីរបស់អ្នកស្រី សុខហួរ បានធ្វើឲ្យរដ្ឋសភា និងក្រសួងយុត្តិធម៌ ត្រូវបានគេមើលឃើញថា "កំពុងតែត្រូវបន្ទោស" ទាក់ទិននឹងថាតើអ្នកណាត្រូវទទួលខុសត្រូវក្នុងការផ្តល់អភ័យឯកសិទ្ធិសភាជូនដល់អ្នកស្រីវិញ។[13] អ្នកស្រី សុខហួរ បានជំទាស់ថាពុំមែនជាតួនាទីរបស់អ្នកស្រីក្នុងស្នើសុំផ្តល់អភ័យឯកសិទ្ធិសភារបស់ខ្លួនមកវិញនោះទេ ហើយចំណុចនេះត្រូវបានគាំទ្រដោយលោក សុក សំអឿន នាយកប្រតិបត្តិក្រុម

[13] *ឌីភ្នំពេញប៉ុស្តិ៍* ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១១៖"ស្ថាប័នជាតិស្តីបន្ទោសគ្នាលើបញ្ហាអ្នកស្រី មួរ សុខហួរ" អាចស្វែងរកបានតាមរយៈ៖ http://www.phnompenhpost.com/index.php?option=com_jcs&view=jcs&layout=form&Itemid=555.

អ្នកច្បាប់ការពារសិទ្ធិមនុស្សកម្ពុជា ដែលលើកឡើងថានេះជាតួនាទីរបស់ក្រសួងយុត្តិធម៌ក្នុងការទំនាក់-ទំនងទៅរដ្ឋសភា ដោយសារតែខ្លួនជាអ្នកផ្តួចផ្តើមធ្វើសំណើដំបូងដើម្បីឲ្យដកអភ័យឯកសិទ្ធិសភារបស់អ្នកស្រី សុខហួរ។[14]

ករណីរបស់អ្នកស្រី សុខហួរ គួសបញ្ជាក់អំពីភាពមិនច្បាស់លាស់ ភាពមិនស៊ីសង្វាក់គ្នា ភាពធ្វេសប្រហែសដែលជាចន្លោះប្រហោងនៅក្នុង ច.ល.ត.រ ដែលជាអត្ថបទច្បាប់ពុំមានគោលគំនិតច្បាស់លាស់ ហើយគួរតែមានកិច្ចខិតខំប្រឹងប្រែងក្នុងការដោះស្រាយនូវចំណុចខ្វះខាតទាំងអស់នេះដើម្បីបញ្ចៀសកំហុសឆ្គងក្នុងការអនុវត្ត ច.ល.ត.រ នាពេលអនាគត។ សំខាន់ជាងនេះទៀត បទប្បញ្ញត្តិទាំងឡាយត្រូវតែបានព្រាង និងអនុម័ត ហើយដែលដាក់ចេញនូវនីតិវិធីសម្រាប់ផ្តល់អភ័យឯកសិទ្ធិសភាឡើងវិញ នៅក្នុងករណីដែលមិនបានទទួលការលើកលែងទោសពីព្រះមហាក្សត្រ និងពុំមានការប្រកាសថាគ្មានទោស។ ច.ល.ត.រ គួរតែមានចែងយ៉ាងច្បាស់លាស់ថា តើការផ្តល់អភ័យឯកសិទ្ធិសភាឡើងវិញគឺត្រូវកើតមានជាស្វ័យប្រវត្តិ ក្រោយពីអំឡុងពេលជាក់លាក់ណាមួយ ឬ ប្រសិនជាមិនដូច្នេះទេ ថាតើដំណើរការយ៉ាងណាដែលតំណាងរាស្ត្រ និង/ឬ ស្ថាប័នពាក់ព័ន្ធត្រូវតែគោរពតាមជាដាច់ខាត។ បើសិនជាមិនមានកំណត់ដូច្នេះទេ បញ្ហាដូចគ្នាដដែលនេះនឹងកើតមានឡើងទៀតនៅពេលអនាគត ដែលធ្វើឲ្យគ្រោះថ្នាក់ដល់លទ្ធិប្រជាធិបតេយ្យក្នុងប្រទេសកម្ពុជា។

ការផ្តន្ទាទោសព្រហ្មទណ្ឌ និងការឈរឈ្មោះជាបេក្ខជនបោះឆ្នោត

មាត្រា៣៤ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ (“ច.ប.ជ.ត.រ”) បញ្ញត្តអំពីលក្ខ-ខណ្ឌដែលប្រជាពលរដ្ឋត្រូវបានច្រានចោលនូវសិទ្ធិក្នុងការឈរឈ្មោះជាបេក្ខជនបោះឆ្នោត។ មាត្រានេះបញ្ញត្តថា “*ជនដែលត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ*” គ្មានសិទ្ធិឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។ ហេតុដូច្នេះ ពុំមែនជាការដកអភ័យឯកសិទ្ធិសភាផ្ទាល់ ដែលរារាំងបេក្ខជនមានសក្តានុពលពីការឈរឈ្មោះឲ្យគេបោះឆ្នោតនោះទេ ប៉ុន្តែគឺការដែលអភ័យឯកសិទ្ធិសភាមិនត្រូវបានផ្តល់ឲ្យឡើងវិញ ប្រសិនជាតំណាងរាស្ត្រនោះត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគារ។ ចំណុចនេះមានន័យថាបេក្ខជនដែលមានសក្តានុពលមានសិទ្ធិឈរឈ្មោះឲ្យគេបោះឆ្នោតត្រឹមត្រូវតាមច្បាប់ ទោះបីជាអភ័យឯកសិទ្ធិសភារបស់តំណាងរាស្ត្រនោះមិនទាន់ត្រូវបានផ្តល់ជូនឡើងវិញនៅពេលបោះឆ្នោតក្តី ដរាបណាតំណាងរាស្ត្រនោះមិនត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគារ។

---

[14] *ឌីភ្នំពេញប៉ុស្តិ៍* ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១១៖ “ស្ថាប័នជាតិស្តីបន្ទោសគ្នាលើបញ្ហាអ្នកស្រី មួរ សុខហួរ” អាចស្វែងរកបានតាមរយៈ៖ http://www.phnompenhpost.com/index.php?option=com_jcs&view=jcs&layout=form&Itemid=555.

"ការផ្តល់ជូននូវគុណសម្បត្តិឡើងវិញ"៖ ការផ្តល់ឲ្យមាននីតិសម្បទាឡើងវិញតាមក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

ក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧ ចែងអំពី"ការផ្តល់ជូននូវគុណសម្បត្តិឡើងវិញ" តាមមាត្រា៥៣៤ ដល់ មាត្រា៥៤១ និងធ្វើជាមូលដ្ឋានដែលរាជរដ្ឋាភិបាលកម្ពុជា បានពិចារណាលើករណីរបស់អ្នកស្រី សុខហួរ។ ស្របពេលដែលអភ័យឯកសិទ្ធិសភារបស់អ្នកស្រី សុខហួរ មិនគួរត្រូវបានដកដូចទម្លឹករណ៍ ដែលបានលើកឡើងខាងលើទេនោះ មិនគួរមានភាពចាំបាច់ក្នុងការអនុវត្តន៍តាមបទប្បញ្ញត្តិទាំងឡាយ ដែលកំណត់ដោយក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧ នោះទេ។ ក្នុងករណីណាក៏ដោយ មានការកត់សម្គាល់ថា ក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧ ខកខានមិនបានចែងនូវមូលដ្ឋានឲ្យបានគ្រប់គ្រាន់អំពីការបដិសេធនូវសំណើសុំឲ្យផ្តល់គុណសម្បត្តិឡើងវិញ និងមិនសំដៅឲ្យបានជាក់លាក់តែទៅលើអភ័យឯកសិទ្ធិសភានោះទេ។ ដរាបណាដែលមានអត្ថបទច្បាប់ដូចជា ច.ល.ត.រ ដែលគ្របដណ្តប់លើឋានៈតំណាងរាស្ត្រយ៉ាងជាក់លាក់ ឧបាស្រ័យលើក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧ បញ្ជាក់ពីកំហុសឆ្គងក្នុងច្បាប់បែបនេះ និងបង្ហាញថា ច.ល.ត.រ មិនទាន់មានលក្ខណៈគ្រប់គ្រាន់ក្នុងការដោះស្រាយលើបញ្ហានៃការផ្តល់អភ័យឯកសិទ្ធិសភាឡើងវិញយ៉ាងមានប្រសិទ្ធភាពនោះទេ។

សាវតារបន្ថែម៖ ករណីលោក សម រង្ស៊ី និងសមាជិក គ.ស.រ ជាទៀងទៀត[15]

ករណីរបស់អ្នកស្រី មូរ សុខហួរ គឺជាករណីមួយក្នុងចំណោមករណីបន្តបន្ទាប់គ្នារបស់សមាជិក គ.ស.រ ដែលត្រូវបានដកអភ័យឯកសិទ្ធិសភា។ ប្រធាន គ.ស.រ លោក សម រង្ស៊ី បច្ចុប្បន្នកំពុងនិរទេសខ្លួននៅក្នុងប្រទេសបារាំង ដើម្បីគេចវេះពីការជាប់ពន្ធនាគារយៈពេល១២ឆ្នាំ ដោយផ្អែកលើការចោទប្រកាន់ដែលត្រូវបានគេចាត់ទុកជាទូទៅថាត្រូវបានធ្វើឡើងដោយមានចរិតលក្ខណៈនយោបាយ (សូមមើលផ្នែកខាងក្រោម)។ លោក សម រង្ស៊ី ត្រូវបានដកអភ័យឯកសិទ្ធិសភាចំនួនបីលើក។ នៅឆ្នាំ២០០៥ លោក សម រង្ស៊ី បានអះអាងតាមរយៈវិទ្យុសំបុកឃ្មុំថាសម្តេចក្រុមព្រះ រណឫទ្ធិ ត្រូវបានលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន សូកប៉ាន់កាលពីឆ្នាំ២០០៤ ដើម្បីបង្កើតជាសម្ព័ន្ធគណបក្សជាមួយនឹង គ.ប.ក[16] និងត្រូវបានបង្ខំឲ្យភៀសខ្លួនចេញពីប្រទេស តែត្រឡប់ចូលប្រទេសវិញបន្ទាប់ពីទទួលបានការលើកលែងទោសពីព្រះមហាក្សត្រ សីហមុនី កាលពីឆ្នាំ២០០៦។ ការដកលើកទីពីរគឺនៅក្នុងខែវិច្ឆិកា ឆ្នាំ២០០៩ បន្ទាប់ពីលោក សម រង្ស៊ី

[15] *ម.ស.ម.ក* ៖"ការវិភាគផ្នែកច្បាប់៖ ករណីនៃព្រះរាជាណាចក្រកម្ពុជា ទល់នឹងអ្នកស្រី មូរ សុខហួរ" អាចស្វែងរកបានតាមរយៈ៖ http://www.cchrcambodia.org/index_old.php?url=media/media.php&p=analysis_detail.php&anid=11&id=5.

[16] *ក.ឧ.ស.ម.ក* ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥៖"អ្នកតំណាងពិសេសបញ្ចេញក្តីបារម្ភជាខ្លាំងលើសាលក្រមបរិហារកេរ្តិ៍ប្រឆាំងនឹងមេបក្សប្រឆាំងលោក សម រង្ស៊ី" អាចស្វែងរកបានតាមរយៈ៖ http://www.ohchr.org/EN/NewsEvents/Pages/DisplayNews.aspx?NewsID=4824&LangID=E.

បានចោទប្រកាន់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដោយការរិះគន់ដែលនាំឲ្យរាំងស្ទះប្រឆាំងនឹងការគ្រប់គ្រងមិនត្រឹមត្រូវរបស់រាជរដ្ឋាភិបាលកម្ពុជា នូវក្នុងប្រព័ន្ធតុលាការ និងនយោបាយរបស់ប្រទេស។[17] ក្នុងហានៈជាមេដឹកនាំគណបក្សជំទាស់ដែលហ៊ាននិយាយដោយឥតសំចៃមាត់ លោក សម រង្ស៊ី មិនត្រឹមតែគូសបញ្ជាក់អំពីការតូចចង្អៀតនូវលំហនៃលទ្ធិប្រជាធិបតេយ្យនៅប្រទេសកម្ពុជានោះទេ តែលោកក៏ថែមទាំងចោទប្រកាន់ចំពោះរាជរដ្ឋាភិបាលកម្ពុជា អំពីការគ្រប់គ្រងបញ្ហាសេដ្ឋកិច្ចដោយមិនត្រឹមត្រូវតាមរយៈសកម្មភាពដូចជាការផ្តល់ដី និងធនធានធម្មជាតិផ្សេងៗទៅឲ្យវិនិយោគិនបរទេស។ បន្ទាប់ពីសេចក្តីសម្រេចផ្តន្ទាទោសរបស់តុលាការលើរូបលោក សម រង្ស៊ី ក្នុងឆ្នាំ២០០៩ លោកបានទទួលអភ័យឯកសិទ្ធិសភាមកវិញ ក្រោយពី គ.ស.រ បានបង់ប្រាក់ពិន័យចំនួន២.៥០០ដុល្លាអាមេរិក។[18]

ករណីចុងក្រោយបំផុតនៅចុងឆ្នាំ២០០៩ លោក សម រង្ស៊ី ត្រូវបានចោទប្រកាន់យ៉ាងចម្រូងចម្រាសពីបទញុះញង់ជាតិសាសន៍ ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរដ្ឋ ការក្លែងឯកសារសាធារណៈ និងការផ្តល់ព័ត៌មានមិនពិត បន្ទាប់ពីរូបលោក និងអ្នកភូមិមកពីខេត្តស្វាយរៀងបានដកបង្គោលតម្រុយព្រំដែនបណ្តោះអាសន្នចំនួន៦ ដែលពួកគាត់បានអះអាងបង្ហាញពីការទន្ទ្រានរបស់ប្រទេសវៀតណាមមកលើដែនដីនៃប្រទេសកម្ពុជា។[19] សវនាការលើរូបលោក សម រង្ស៊ី ត្រូវបានគេមើលឃើញជាទូទៅថាមានចរិតលក្ខណៈនយោបាយ និងបានធ្វើឡើងយ៉ាងមានប្រសិទ្ធភាពក្នុងការធ្វើឲ្យ គ.ស.រ ស្ថិតក្នុងស្ថានភាពមួយទន់ខ្សោយ ដោយឲ្យ "*ទម្លាក់ប្រជាប្រិយភាពរបស់គណបក្ស និងបន្ថយនូវថាមពលដែលគណបក្សមានបន្តិចម្តងៗក្នុងដំណើរថយក្រោយបន្ថែមទៀត*"។[20] ស្ថានភាពនៅធ្មឹងដដែលបែបនេះអាចផ្លាស់ប្តូរដោយមានការរួមបញ្ចូលគ្នាថ្មីៗនេះរវាង គ.ស.រ ជាមួយនឹងគណបក្សសិទ្ធិមនុស្ស ("គ.ស.ម") ដើម្បី

---

[17] *គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល)* ខែកុម្ភៈ ឆ្នាំ២០១២៖"លទ្ធិប្រជាធិបតេយ្យ ការបោះឆ្នោត និងកំណែទម្រង់នៅកម្ពុជា" អាចស្វែងរកបានតាមរយៈ៖ http://www.comfrel.org/images/others/1265785063Comfrel-Cambodia%20Democratic%20Reform%202009-En-Final.pdf.

[18] *គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល)* ខែកុម្ភៈ ឆ្នាំ២០១២៖"លទ្ធិប្រជាធិបតេយ្យ ការបោះឆ្នោត និងកំណែទម្រង់នៅកម្ពុជា" អាចស្វែងរកបានតាមរយៈ៖ http://www.comfrel.org/images/others/1265785063Comfrel-Cambodia%20Democratic%20Reform%202009-En-Final.pdf.

[19] *អង្គការឃ្លាំមើលសិទ្ធិមនុស្ស* ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១០៖"កម្ពុជា៖ សវនាការរបស់មេបក្សប្រឆាំងលោក សម រង្ស៊ី ជារឿងល្ខោន" អាចស្វែងរកបានតាមរយៈ៖ http://www.unhcr.org/refworld/docid/4b6abe8dc.html; និង *ម.ស.ម.ក* ខែកុម្ភៈ ឆ្នាំ២០១១៖"ការវិភាគលើមូលដ្ឋានច្បាប់សម្រាប់ការផ្តន្ទាទោស និងយុត្តិធម៌នៃនីតិវិធីរបស់តុលាការនៅក្នុងករណីព្រហ្មទណ្ឌប្រឆាំងនឹងលោក សម រង្ស៊ី" អាចស្វែងរកបានតាមរយៈ៖ http://www.cchrcambodia.org/index_old.php?url=media/media.php&p=analysis_detail.php&anid=1&id=5.

[20] *លោក ហ្គេឌី អេស្ពេ*៖"កម្ពុជាក្នុងឆ្នាំ២០១១៖ កំណែទម្រង់មូលធនមិនតាមលទ្ធិប្រជាធិបតេយ្យសេរី និងរបបអំណាចផ្តាច់ការ" នៅក្នុងកិច្ចការអាស៊ីអាគ្នេយ៍ ឆ្នាំ២០១២ ទំព័រទី១១២។

បង្កើត គ.ស.ជ ដែលត្រូវបានព្យាករណ៍ថានឹង"ធ្វើឲ្យរលក"នៅក្នុងការបោះឆ្នោតនាពេលឆាប់ៗខាងមុខ នេះ។[21] តែទោះជាយ៉ាងនេះក្តី ហាក់ដូចជាថា គ.ប.ក គឺទំនងនឹងបន្តគ្របដណ្តប់ក្នុងរដ្ឋសភា និង ព្យាបាទលើរូបលោក សម រង្ស៊ី ហើយមន្ទិលសង្ស័យបែបនេះត្រូវបានគាំទ្រដោយរបាយការណ៍ថ្មីៗនានា ដែលថាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលគ្រប់គ្រងដោយរដ្ឋាភិបាលនឹងរារាំងលោក សម រង្ស៊ី ដែលជាប្រធាន គ.ស.ជ ដែលទើបបង្កើតថ្មីផងនោះ មិនឲ្យធ្វើយុទ្ធនាការនៅក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៅក្នុងខែកក្កដា ឆ្នាំក្រោយនោះទេ។[22]

មិនដូចករណីអ្នកស្រី មូរ សុខហួរ បើយោងតាម ច.ប.ជ.ត.រ លោក សម រង្ស៊ី នឹងពុំមានសិទ្ធិឈរឈ្មោះជាបេក្ខជនជ្រើសតាំងតំណាងរាស្ត្រនោះទេ ដោយសារតែរូបលោកត្រូវបានតុលាការផ្តន្ទាទោសពីបទព្រហ្មទណ្ឌដែលទទួលទោសពន្ធនាគារ។ ទោះជាយ៉ាងនេះក្តី ដូចដែលបានលើកឡើងពីខាងលើ ដែលថាភាពអយុត្តិធម៌ពុំមែនផ្អែកតែលើច្បាប់ផ្ទាល់តែប៉ុណ្ណោះនោះទេ ប៉ុន្តែផ្អែកតាមចរិតលក្ខណៈនៃការផ្តន្ទា-ទោសផងដែរ។ សវនាការលើរូបលោក សម រង្ស៊ី ស្ថិតនៅឆ្ងាយពីបទដ្ឋាននៃការទទួលបានសិទ្ធិដំនុំជម្រះក្តីដោយយុត្តិធម៌ជាលក្ខណៈអន្តរជាតិ៖ តុលាការត្រូវបានបិទពីសាធារណៈជន អ្នកការសែត និងអង្គការឃ្លាំមើលសិទ្ធិមនុស្ស ហើយលោក សម រង្ស៊ី ត្រូវបានជំនុំជម្រះ*កំបាំងមុខ* និងព្រមទាំងត្រូវបានច្រានចោលសិទ្ធិស្នើសុំឲ្យពិនិត្យកស្តុតាងប្រឆាំងនឹងរូបលោកថែមទៀត។[23] លោក សម រង្ស៊ី ត្រូវបានតុលាការផ្តន្ទាទោសឲ្យជាប់ពន្ធនាគារយៈពេលពីរឆ្នាំពីបទចោទប្រកាន់ពីរដំបូងរួមមាន៖ ញុះញង់ឲ្យមានការស្អប់ខ្ពើមជាតិសាសន៍ និងបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរដ្ឋ កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០១០ ដែលទោសនេះត្រូវបានតម្កល់បន្ទាប់ពីបណ្តឹងឧទ្ធរណ៍។ ក្រោយមកទៀត លោក សម រង្ស៊ី ត្រូវបានតុលាការរកឃើញពិរុទ្ធភាពនៃការចោទប្រកាន់ពីបទក្លែងឯកសារសាធារណៈ និងផ្តល់ព័ត៌មានមិនពិត ហើយត្រូវបានតុលាការផ្តន្ទាទោសឲ្យជាប់ពន្ធនាគារយៈពេលដប់ឆ្នាំនៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១០។

ជាការឆ្លើយតបទៅនឹងការស្នើសុំពីគណបក្សជំទាស់ថ្មីៗនេះដើម្បីអនុញ្ញាតឲ្យលោក សម រង្ស៊ី អាចត្រឡប់មកប្រទេសកម្ពុជាវិញឲ្យទាន់ពេលសម្រាប់ការបោះឆ្នោតនៅឆ្នាំក្រោយ អង្គភាពព័ត៌មាន និង

---

[21] *វិទ្យុសម្លេងសហរដ្ឋអាមេរិក (វីអូអេ)* ថ្ងៃទី៨ ខែសីហា ឆ្នាំ២០១២៖"អ្នកវិភាគនិយាយថា ការបញ្ចូលគ្នារបស់គណបក្សប្រឆាំងនឹងធ្វើឲ្យរស់រវើក" អាចស្វែងរកបានតាមរយៈ៖ http://www.voacambodia.com/content/opposition-merger-making-waves-analysts-say/1474944.html.

[22] *អង្គការឃ្លាំមើលសិទ្ធិមនុស្ស* ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១២៖"កម្ពុជា៖ បន្ទាប់ពីថ្នាក់ដឹកនាំសហរដ្ឋអាមេរិក និងអាស៊ានចាកចេញ អ្នកសារព័ត៌មានរិះគន់រដ្ឋាភិបាលត្រូវជាប់ពន្ធនាគារ" អាចស្វែងរកបានតាមរយៈ៖ http://www.hrw.org/news/2012/07/17/cambodia-after-us-asean-leave-media-critic-jailed.

[23] *អង្គការឃ្លាំមើលសិទ្ធិមនុស្ស* ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១០៖"កម្ពុជា៖ សវនាការរបស់មេបក្សប្រឆាំងលោក សម រង្ស៊ី ជារឿងល្ខោន" អាចស្វែងរកបានតាមរយៈ៖http://www.unhcr.org/refworld/docid/4b6abe8dc.html.

ប្រតិកម្មហ៍សនៅទីស្តីការគណៈរដ្ឋមន្ត្រីប្រកាសលុបចោលសេចក្តីសង្ឃឹមទាំងនោះភ្លាមៗ ដោយថ្លែងថាមេដឹកនាំគណបក្សជំទាស់នឹងមិនត្រូវអនុញ្ញាតឲ្យត្រឡប់មកវិញនោះទេ និងបញ្ជាក់ថា "ពុំមានការសម្រុះសម្រួលទៀតនៅក្នុងសតវត្សរ៍នេះនោះទេ"។[24]

លោក **ចាន់ ចេង** គឺជាឧទាហរណ៍មួយទៀតនៃតំណាងរាស្ត្ររបស់ គ.ស.រ ដែលត្រូវបានដកអភ័យឯកសិទ្ធិសភារបស់ខ្លួន ដើម្បីឲ្យមានការផ្តន្ទាទោសលើរូបលោកចំពោះបទចោទប្រកាន់ដែលមានចរិតលក្ខណៈនយោបាយ។ អភ័យឯកសិទ្ធិរបស់លោក ចាន់ ចេង ត្រូវបានដកនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១១ បន្ទាប់ពីលោកត្រូវបានចោទប្រកាន់ពីបទជួយលោក មាស ប៉េង ដែលជាសកម្មជន គ.ស.រ ដែលជាបុគ្គលតុលាការត្រូវការសម្រាប់ការសាកសួរទាក់ទិននឹងវិវាទដីធ្លីរវាងអ្នកភូមិ និងមន្ត្រី គ.ប.ក ដើម្បីគេចផុតពីការឃុំខ្លួនបណ្តោះអាសន្ន។[25] បទ *"ផ្តល់ជំនួយដល់ចារី"* ត្រូវផ្តន្ទាទោសឲ្យជាប់ពន្ធនាគារពីមួយឆ្នាំទៅបីឆ្នាំ អនុលោមតាមមាត្រា៥៤៤ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩។ ទោះជាយ៉ាងនេះក្តី ទំនាក់ទំនងរវាងលោក មាស ប៉េង និងលោក ចាន់ ចេង គឺមិនស៊ីជម្រៅនោះទេ។[26] បន្ទាប់ពីត្រូវបានតុលាការកោះហៅដើម្បីសាកសួរនៅក្នុងខែកញ្ញា ឆ្នាំ២០១១ លោក មាស ប៉េង ត្រូវបានតុលាការសម្រេចឃុំខ្លួនដោយគ្មានដីកា។ ដោយសារតែតុលាការមិនទាន់បានចេញដីកាឃុំខ្លួនលោក មាស ប៉េង មេធាវីរបស់លោកបានទទូចថាលោក មាស ប៉េង ត្រូវតែអនុញ្ញាតឲ្យចាកចេញ។ បន្ទាប់មក លោក មាស ប៉េង ត្រូវបាននាំចេញពីតុលាការតាមរថយន្តដោយលោក ចាន់ ចេង មុនពេលដែលលោកបាត់ខ្លួន។[27] អំពើដឹកលោក មាស ប៉េង ចេញតាមរថយន្តនេះហើយដែលឈានដល់ការចោទប្រកាន់លើរូបលោក ចាន់ ចេង ថាបានផ្តល់ជំនួយដល់ការ "គេចខ្លួន"របស់លោក មាស ប៉េង។ ការចោទប្រកាន់ទាំងនេះគឺធ្វើឡើងដោយគ្មានមូលដ្ឋាន៖ ពុំមានលិខិតត្រូវបានចុះហត្ថលេខាបញ្ជាឲ្យឃុំខ្លួនលោក មាស ប៉េង និងហេតុដូច្នេះអំពើដឹកលោកចេញពីតុលាការតាមរថយន្តច្បាស់ជាមិនមែនជាអំពើខុសច្បាប់នោះទេ។ ជាក់ស្តែង មាត្រា២១៩ ដល់មាត្រា២២២ នៃ

---

[24] *ឌីវ័ខមបូវ័ឌដេលី* ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១២៖"រដ្ឋាភិបាលនិយាយថាលោក សម រង្ស៊ី នឹងមិនត្រូវបានអនុញ្ញាតឲ្យត្រឡប់មកវិញទេ" ទំព័រទី១៦។

[25] *វីអូអេខ្មែរ* ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១៖"តំណាងរាស្ត្រគណបក្សប្រឆាំងត្រូវបានចោទប្រកាន់បន្ទាប់ពីការព្យួរអភ័យឯកសិទ្ធិសភា" អាចស្វែងរកបានតាមរយៈ៖ http://www.voacambodia.com/content/opposition-lawmaker-charged-after-immunity-suspension-136545183/1354784.html.

[26] *ឌីភ្នំពេញប៉ុស្តិ៍* ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១២៖"ជនភៀសខ្លួនរបស់គណបក្សប្រឆាំងកំពុងលាក់ខ្លួននៅទីភ្លឺ" អាចស្វែងរកបានតាមរយៈ៖ http://www.phnompenhpost.com/index.php/2012061356760/National-news/srp-refugee-was-hiding-in-plain-sight.html.

[27] *លីកាដូ* ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១១៖"លទ្ធិប្រជាធិបតេយ្យកម្ពុជាទទួលរងការវាយប្រហារមួយទៀត ខណៈដែលរដ្ឋសភាដកអភ័យឯកសិទ្ធិតំណាងរាស្ត្រមកពីគណបក្សប្រឆាំង" អាចស្វែងរកបានតាមរយៈ៖http://www.licadho-cambodia.org/pressrelease.php?perm=265.

ក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧ កំណត់នូវលក្ខខណ្ឌអំពីជនណាម្នាក់អាចត្រូវបានឃុំខ្លួនបណ្តោះអាសន្ន ដែលមិនបានធ្វើឡើងត្រឹមត្រូវនៅក្នុងករណីនេះ។ ជាជំនួសវិញ ឧប្បត្តិហេតុនេះបានផ្តល់នូវការបិទបាំងយ៉ាងស្រួលដើម្បីព្យាបាទតំណាងរាស្ត្រគណបក្សជំទាស់មុនការបោះឆ្នោតថ្នាក់តំបន់ និងថ្នាក់ជាតិដែលនឹងប្រព្រឹត្តទៅក្នុងឆ្នាំ២០១២ និង២០១៣។

ករណីពាក់ព័ន្ធនឹងលោក មាស ប៉ែង កាន់តែចម្លែកទៅៗ។ លោក មាស ប៉ែង ត្រូវបានចាប់ខ្លួនជាថ្មីកាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១២ នៅឯផ្ទះរបស់លោកស្ថិតក្នុងខេត្តកណ្តាល។ ក្រោយមកមានព័ត៌មានផុសចេញមកថាពេលវេលាជាច្រើនរបស់លោកក្នុង"ការលាក់ខ្លួន" គឺលោកចំណាយពេលនៅក្នុងផ្ទះនោះឯង ដែលនៅក្នុងអំឡុងពេលនោះលោកត្រូវបានបោះឆ្នោតជាជំទប់ទី១នៃឃុំបន្ទាយដែក ដែលជាតំណែងមួយខ្ពស់ជាងកាលដែលលោកទទួលនៅពេលចាប់ខ្លួន។ សមាជិក គ.ស.រ ជាច្រើនបានអះអាងថាការកំណត់រយៈពេលនៃការចាប់ខ្លួនជាថ្មីរបស់លោក មាស ប៉ែង គឺជាឥរិយាបថនយោបាយ ដែលបានធ្វើឡើងភ្លាមៗបន្ទាប់ពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់កាលពីថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១២ និងស្របពេលដែលមានភាពច្បាស់លាស់ដែលថាកន្លែងដែលលោកលាក់ខ្លួនត្រូវបានអាជ្ញាធរមូលដ្ឋានដឹងទៅហើយនោះ។ ភាពបត់បែននៃព្រឹត្តិការណ៍នេះនាំឲ្យមានចំណោទលើធម្មានុរូបភាពនៃការចោទប្រកាន់ដែលបានធ្វើឡើងប្រឆាំងនឹងលោក ចាន់ ចេង ដោយសារតែប្រសិនជាលោក មាស ប៉ែង ពិតជាមិនបានគេចខ្លួនទេនោះតែលោករស់នៅក្នុងផ្ទះដែលមើលឃើញពីសំណាក់អាជ្ញាធរ លោក ចាន់ ចេង មិនគួរត្រូវបានជាប់ពាក់ព័ន្ធនៅក្នុង"ការគេចខ្លួន"នោះទេ។ ករណីរបស់លោក ចាន់ ចេង ផ្តល់ជាឧទាហរណ៍មួយទៀតនៃការដកអភ័យឯកសិទ្ធិសភាតាមអំពើចិត្តសម្រាប់ហេតុផលនយោបាយ ដែលធ្វើឲ្យអន់ថយនូវគោលបំណងជារួមរបស់អភ័យឯកសិទ្ធិសភា។

សេចក្តីសន្និដ្ឋាន/អនុសាសន៍៖

តុលាការរបស់ប្រទេសកម្ពុជាត្រូវបានគេចាត់ទុកជាទូទៅថាជាស្ថាប័នដែលងាយបត់បែនទៅតាមឆន្ទៈរបស់ គ.ប.ក។ រាជរដ្ឋាភិបាលកម្ពុជាកំពុងតែប្រើប្រាស់ដំណើរការតាមផ្លូវច្បាប់ច្រើនឡើងៗ ដើម្បីបំភិតបំភ័យក្រុមជំទាស់ដែលអនុវត្តសិទ្ធិសេរីភាពមូលដ្ឋានខាងការបញ្ចេញមតិរបស់ពួកគេផ្ទុយទៅនឹងផលប្រយោជន៍របស់រាជរដ្ឋាភិបាលកម្ពុជា ឬ គ.ប.ក ដូចដែលយើងបានឃើញករណីរបស់អ្នកស្រី មូរ សុខហួរ លោក សម រង្ស៊ី និងលោក ចាន់ ចេង។

ការដាក់កំហិត និងការរឹតត្បិតទៅលើសិទ្ធិសេរីភាពខាងការបញ្ចេញមតិ ដូចជាការដកអភ័យឯកសិទ្ធិសភា ត្រូវតែធ្វើការបកស្រាយក្នុងផ្លូវចង្អៀត ហើយដែល ច.ល.ត.រ ត្រូវបានអនុវត្តទាំងមិនច្បាស់លាស់

និងមានកំហុសឆ្គងជាច្រើន។ និយាយម្យ៉ាងទៀត អភ័យឯកសិទ្ធិសភាមិនគួរត្រូវបានដកនៅក្នុងករណីដែលពុំមានទោសពន្ធនាគារនោះទេ ដូចជាករណីរបស់អ្នកស្រី មូរ សុខហួរ ជាដើម។ ដោយផ្អែកលើទម្រង់នៃការបំភិតបំភ័យប្រឆាំងនឹងតំណាងរាស្ត្ររបស់គណបក្សជំទាស់ មានភាពច្បាស់លាស់ណាស់ថាអភ័យឯកសិទ្ធិសភាជាបញ្ញត្តិគ្មានន័យអ្វីសោះនៅក្នុងច្បាប់កម្ពុជាក្នុងស្ថានភាពនាពេលបច្ចុប្បន្ននេះ ហើយសេចក្តីសម្រេចដកអភ័យឯកសិទ្ធិត្រូវបានធ្វើឡើងដោយរដ្ឋសភា ដែលគ្របដណ្តប់ដោយ គ.ប.ក និងត្រូវបានដាក់ទណ្ឌកម្មតាមរយៈតុលាការដែលលក្ខណៈនយោបាយ។ បន្ថែមលើនេះទៀត លក្ខខណ្ឌតម្រូវសម្រាប់ការដក និងការផ្តល់ឡើងវិញនៃអភ័យឯកសិទ្ធិសភាគួរតែត្រូវបានរួមបញ្ចូល និងតាក់តែងឡើងវិញក្រោមអត្ថបទច្បាប់ដែលកំណត់យ៉ាងជាក់លាក់មួយ ហេតុដូច្នេះហើយស្ថាប័នតុលាការកម្ពុជាមានសំណុំនៃវិធានកំណត់ជាក់លាក់ដែលតុលាការអាចបំពេញមុខងារបានយ៉ាងត្រឹមត្រូវ។

សមាជិក គ.ស.រ និងគណបក្សតូចៗដទៃទៀតគួរតែត្រូវបានផ្តល់អភ័យឯកសិទ្ធិសភាឡើងវិញ និងវិធានការនានាគួរតែត្រូវបានធ្វើឡើងដើម្បីបញ្ចៀសការប្រើប្រាស់ខុសនៃប្រព័ន្ធយុត្តិធម៌ដោយ គ.ប.ក ឬសមាជិកគណបក្សភាគច្រើននាពេលអនាគត។ ដើម្បីបង្ការការរំលោភបំពាននាពេលអនាគត ច្បាប់ទាក់ទិននឹងអភ័យឯកសិទ្ធិសភាគួរតែត្រូវបានបង្កើតឡើង និងត្រូវតែបានកែសម្រួលដោយអង្គនីតិបញ្ញត្តិ និងត្រូវតែអនុវត្តដោយតុលាការប៉ុណ្ណោះ។ ប្រសិនជាតំណាងរាស្ត្រ ឬ អង្គនីតិប្រតិបត្តិ ត្រូវបានផ្តល់អំណាចក្នុងការបង្កើត និងអនុវត្តច្បាប់ទាំងនេះផង ស្ថានភាពនៃការរំលោភបំពាននានានឹងបន្តកើតមានដោយជៀសមិនរួចនោះទេ។ ម.ស.ម.ក សូមផ្តល់យោបល់ថាច្បាប់ទាំងឡាយដែលទាក់ទងនឹងតំណាងរាស្ត្រត្រូវតែធ្វើវិសោធនកម្មដើម្បីដាក់ឲ្យអនុវត្តដោយតុលាការប្រសើរជាងរដ្ឋសភាខ្លួនឯង ដែលនឹងបំពេញមុខងារជាអ្នកត្រួតពិនិត្យប្រឆាំងនឹងការរំលោភបំពានដោយគណបក្សភាគច្រើននាពេលអនាគត នៅខណៈដែលវិធានការបន្ទាន់ជាច្រើនទៀតគួរតែត្រូវបានធ្វើឡើងដើម្បីផ្តល់អំណាច និងអាចឲ្យគណបក្សជំទាស់មានសេរីភាពក្នុងការនិយាយស្តី។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោក អ៊ូ វីរៈ តាមរយៈទូរសព្ទ៖ (+៨៥៥ (០) ១២ ៤០៤ ០៥១) ឬ អ៊ីម៉ែល៖ ouvirak@cchrcambodia.org ឬ លោក រ៉ូប៊ឺត ហ្វីនច៍ ទីប្រឹក្សាជាន់ខ្ពស់ តាមរយៈទូរសព្ទ៖ (+៨៥៥ (០) ៧៨ ៨០៩ ៩៦០) ឬអ៊ីម៉ែល៖ robert.finch@cchrcambodia.org។

បណ្ណាធិការ៖

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (“ម.ស.ម.ក”) ដែលបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០០២ ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិ-

ប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។

ម.ស.ម.ក ជាសមាជិកនៃដៃគូសន្ធនាអន្តរជាតិដើម្បីសេរីភាពបញ្ចេញមតិ (IFEX) ដែលជាបណ្តាញសាកលសម្រាប់សេរីភាពបញ្ចេញមតិ។

គេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា www.sithi.org ជាជ័យលាភីដែលបានទទួលពានរង្វាន់មូលនិធិនៃការបង្កើតសង្គមព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ ស្ថិតក្នុងប្រភេទ "សិទ្ធិ និងសេរីភាព"។